00809919

E197

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 05 / 2012
ម៉ោង (Time/Heure): 16 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
**Trial Chamber**
**Chambre de Premiere instance**

លេខៈ 97 អ.វ.ត.ក/អ.ជ.ស.ដ

**សាធារណៈ / Public**

<u>សូមគោរពជូន</u>

**លោកសាស្ត្រាចារ្យប្រធានមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត**

**<u>តាមរយៈ</u>** ឯកឧត្តមប្រធានស្តីទីនៃការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

**<u>កម្មវត្ថុ</u>** សូមអញ្ជើញលោកវេជ្ជបណ្ឌិត **លឹម ស៊ីទុតថា** ប្រធានផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅព្រឹកថ្ងៃ ពុធ ទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ នៅសាលសវនាការធំនៃ អ.វ.ត.ក ។

**<u>យោង</u>** របាយការណ៍សុខភាពរបស់ជនជាប់ចោទ អៀង សារី ដែលបានចេញដោយមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១២ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោកប្រធានមេត្តាជ្រាបថា៖ នៅថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១២ លោក អៀង សារី ត្រូវបានបញ្ជូនទៅព្យាបាលនៅផ្នែកសង្គ្រោះបន្ទាន់នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ។ នៅថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១២ ខាងមន្ទីរពេទ្យបានចេញរបាយការណ៍ថា លោក អៀង សារី អាចចេញពីមន្ទីរពេទ្យវិញនៅព្រឹកថ្ងៃ អង្គារ ទី ២២ ខែ ឧសភា ឆ្នាំ ២០១២ តែត្រូវបន្តសម្រាករយៈពេលពីរ (០២) ថ្ងៃ ក្រោយពេលចេញពីមន្ទីរពេទ្យ ។

ដូច្នេះ ដើម្បីឱ្យអង្គជំនុំជម្រះយល់បានច្បាស់អំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ពាក់ព័ន្ធនឹងការចូលរួមសវនាការរបស់គាត់នៅចុងសប្តាហ៍នេះបាន ឬមិនបាននោះ អង្គជំនុំជម្រះសាលាដំបូង សូមអញ្ជើញលោកវេជ្ជបណ្ឌិត **លឹម ស៊ីទុតថា** ដែលជាគ្រូពេទ្យព្យាបាលលោក អៀង សារី មកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះនៅថ្ងៃ ពុធ ទី ២៣ ខែ ឧសភា ឆ្នាំ ២០១២ ដោយចាប់ផ្តើមនៅវេលាម៉ោង ៩.០០ នាទី ព្រឹក នៅសាលសវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដែលមានអាសយដ្ឋាន ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ពោធិ៍សែនជ័យ (អតីតខណ្ឌ ដង្កោ) រាជធានីភ្នំពេញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យលោកវេជ្ជបណ្ឌិត **លីម ស៊ីទុតថា** បានមកឆ្លើយបំភ្លឺនៅចំពោះមុខអង្គជំនុំជម្រះតាមការគួរ។

សូមលោកប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ភ្នំពេញថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១២

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**និល ណុន**